**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**ប្រ.ក/លេខ១១.០៤៥/០៧ គ.ជ.ប.អគ្គ.ពស**

ភ្នំពេញ ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០០៧

# ចំនួនអ្នកសង្កេតការណ៍ដែល គ.ជ.ប បានអនុញ្ញាត

គិតចាប់ពីថ្ងៃទី ០៨ ខែ កញ្ញា ដល់ ថ្ងៃទី ០១ ខែ វិច្ឆកា ឆ្នាំ ២០០៧ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានអនុញ្ញាតឱ្យអ្នកសង្កេតការណ៍ជាតិសរុបចំនួន **១.៤៥៣** នាក់ ក្នុងនោះស្ត្រីមានចំនួន **៤៩៧** នាក់ និងអ្នកសង្កេតការណ៍អន្តរជាតិសរុបចំនួន **២៧** នាក់ ក្នុងនោះស្ត្រីចំនួន **១១** នាក់ ដើម្បីចូលរួមសង្កេតមើលដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ២០០៧ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី ៤ ឆ្នាំ ២០០៨ ។

ចំនួនអ្នកសង្កេតការណ៍ជាតិ ដែល គ.ជ.ប បានអនុញ្ញាតនេះ មកពីសមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ ចំនួន ១០ និងអ្នកសង្កេតការណ៍អន្តរជាតិ មកពីវិទ្យាស្ថានជាតិប្រជាធិបតេយ្យ (**NDI**) និងស្ថានទូតសហរដ្ឋអាមេរិក មានដូចខាងក្រោម ៖

## ~ សមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ ( អ្នកសង្កេតការណ៍ជាតិ )

| | | |
|---|---|---|
| -មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ដាក់អ្នកសង្កេតការណ៍ | ចំនួន **៥០** នាក់ | ក្នុងនោះស្ត្រី **១៦** នាក់ |
| -អង្គការខុមហ្វ្រែល ដាក់អ្នកសង្កេតការណ៍ | ចំនួន **២៧៦** នាក់ | ក្នុងនោះស្ត្រី **៥០** នាក់ |
| -អង្គការនិកហ្វិច ដាក់អ្នកសង្កេតការណ៍ | ចំនួន **៧៤** នាក់ | ក្នុងនោះស្ត្រី **២១** នាក់ |
| -សមាគម សង្គ្រោះកុមារក្រីក្រអនាថាកម្ពុជា ដាក់អ្នកសង្កេតការណ៍ | ចំនួន **១២៣** នាក់ | ក្នុងនោះស្ត្រី **៧៨** នាក់ |
| -អង្គការលើកស្ទួយប្រជាពលរដ្ឋខ្មែរ ដាក់អ្នកសង្កេតការណ៍ | ចំនួន **៥០** នាក់ | ក្នុងនោះស្ត្រី **១៤** នាក់ |
| -អង្គការសហព័ន្ធអភិវឌ្ឍន៍ស្ត្រីកម្ពុជា ដាក់អ្នកសង្កេតការណ៍ | ចំនួន **២៩៧** នាក់ | ក្នុងនោះស្ត្រី **៧៨** នាក់ |
| -អង្គការក្រុមប្រឹក្សាយុវជនកម្ពុជា ដាក់អ្នកសង្កេតការណ៍ | ចំនួន **១៣៤** នាក់ | ក្នុងនោះស្ត្រី **៥៦** នាក់ |
| -អង្គការសហព័ន្ធសិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា ដាក់អ្នកសង្កេតការណ៍ | ចំនួន **៤០** នាក់ | ក្នុងនោះស្ត្រី **០៧** នាក់ |
| -សហគមន៍គ្រួសារអភិវឌ្ឍន៍កសិកម្ម ដាក់អ្នកសង្កេតការណ៍ | ចំនួន **៥២** នាក់ | ក្នុងនោះស្ត្រី **១៥** នាក់ |
| -អង្គការសង្គ្រោះអនាគតកុមារខ្មែរ ដាក់អ្នកសង្កេតការណ៍ | ចំនួន **៣៥៧** នាក់ | ក្នុងនោះស្ត្រី**១២២** នាក់ |
| | សរុប**១.៤៥៣**នាក់ | ក្នុងនោះស្ត្រី **៤៩៧** នាក់ |

## ~ អ្នកសង្កេតការណ៍អន្តរជាតិ

| | | |
|---|---|---|
| - វិទ្យាស្ថានជាតិប្រជាធិបតេយ្យ **NDI** ដាក់អ្នកសង្កេតការណ៍ | ចំនួន **១៥** នាក់ | ក្នុងនោះស្ត្រី **០៧** នាក់ |
| - ស្ថានទូតសហរដ្ឋអាមេរិក ដាក់អ្នកសង្កេតការណ៍ | ចំនួន **១២** នាក់ | ក្នុងនោះស្ត្រី ០៤ នាក់ |
| | សរុប **២៧** នាក់ | ក្នុងនោះស្ត្រី **១១** នាក់ |

សូមបញ្ជាក់ថា ចំពោះអ្នកសង្កេតការណ៍អន្តរជាតិ ត្រូវដាក់ពាក្យសុំសង្កេតការណ៍មក គ.ជ.ប ចាប់ពីថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៧ រហូតដល់ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៨ ហើយអ្នកសង្កេតការណ៍ជាតិ ក៏ត្រូវដាក់ពាក្យសុំសង្កេតការណ៍មក គ.ជ.ប ដែរ ចាប់ពីថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៧ រហូតដល់ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៨។